**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**

**នៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចតេជោ នាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត** !

នៅក្នុងឱកាសដ៏ឧត្តុង្គឧត្តម ប្រពៃថ្លៃថ្លាដែល **សម្តេចតេជោ** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ទទួលបាន កិត្តិយសនៃពានរង្វាន់ « **សមិទ្ធផល អមតៈអាស៊ាន** »ពីឯកឧត្តម **តាន់ស្រី ម៉ៃឃិល យ៉ូវ** នាយកប្រតិបត្តិ នៃវិទ្យាស្ថានយុទ្ធសាស្ត្រ និងភាពជាអ្នកដឹកនាំអាស៊ី ជាប្រធានវេទិកាភាពជាអ្នកដឹកនាំអាស៊ាន លើកទី១៣ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ៦និងទី៧ ខែសីហា ឆ្នាំ២០១៦ នាទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។

តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវមនោសញ្ចេតនា សោមនស្សរីករាយ ឥតឧបមា និងអបអរសាទរយ៉ាងក្លៀវក្លាបំផុត ចំពោះ **សម្តេចតេជោ** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានពានរង្វាន់ដ៏វិសេសវិសាលថ្លៃថ្លានេះ គឺជាការផ្តល់នូវមហាកិត្តិយសដ៏ឧត្តុង្គឧត្តមសម្រាប់ **សម្តេច** និងក្រុមគ្រួសាររបស់ **សម្តេច** ក៏ដូចជាសម្រាប់ប្រទេសជាតិ និងប្រជាជនកម្ពុជាទាំងមូល ហើយកិត្តិយសនៃពានរង្វាន់នេះ គឺពិតជាស័ក្តិសមចំពោះពលិកម្មដ៏ថ្លៃថ្លារបស់ **សម្តេច** ដែលបានបូជាកម្លាំងកាយចិត្ត និងប្រាជ្ញាស្មារតី ក្នុងភាពជាអ្នកដឹកនាំ ដើម្បីសន្តិភាព និងការអភិវឌ្ឍ។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវអំណរសាទរនិងគោរពជូនពរ ចំពោះ **សម្តេចតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំង **បុត្រា បុត្រី ចៅប្រុស ចៅស្រី** ទាំងអស់ជាទីស្រឡាញ់ សូមមានសុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ បញ្ញាញាណភ្លឺថ្លាត្រចះត្រចង់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ទទួលនូវគារវភក្តីភាពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី07 ខែសីហា ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

វិថីហ្សកឌីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៤ អ៊ីមែល៖ Generalsec@mod.gov.kh